សេចក្តីជូនដំណឹងអំពីការសាងសង់

NAME
ADDRESS
CITY ST ZIP

គម្រោងស្តារផ្ទាំងគំនូរនៅអគារចំណតរថយន្តរបស់សាលាក្រុង

ក្រុមហ៊ុមម៉ៅការសាងសង់របស់សាលាក្រុងឈ្មោះ Horizons Construction Co. Int'l, Inc. គ្រោងចាប់ផ្តើមការសាងសង់ នៅអំឡុងរដូវក្តៅឆ្នាំ ២០២៤ ដោយគ្រោងរួចរាល់នៅត្រីមរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ ២០២៤ បើគ្មានការរំខានដោយសារបញ្ហាអាកាសធាតុ ដែលឥតរំពឹងទុកណាមួយ។

ការកែលម្អ និងស្តារឡើងវិញនេះ មានជាអាទិ៍៖

- ស្តារ និងជួសជុលសន្លឹកឥដ្ឋដែលមានរូបគំនូរ
- កែលម្អគុណភាពហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើឲ្យផ្ទាំងគំនូររក្សាគុណភាព និងសម្រស់បានយូរ
- កែលម្អខ្លះៗនៅទីតាំងដែលមានផ្ទាំងគំនូរនោះ

ក្រុមហ៊ុនម៉ៅការសាងសង់នេះ គ្រោងបំពេញកិច្ចការរបស់ខ្លួនចាប់ពីថ្ងៃ **ចន្ទ ដល់ថ្ងៃ សុក្រ ពីម៉ោង ៧ ព្រឹក ដល់ ម៉ោង ៤ ល្ងាច**។ កន្លែងចតរថយន្ត ៤-៦ កន្លែងយ៉ាងតិច នឹងត្រូវប្រើប្រាស់ នៅជាន់លើបំផុតនៃអគារចំណតរថយន្តរបស់សាលាក្រុងអគារ "C" សម្រាប់ការសាងសង់នេះ។ ប៉ុន្តែ គម្រោងប៉ះពាល់តិចតួចបំផុតដល់ការចតយានយន្តរបស់ពលរដ្ឋ។ យើងខ្ញុំនឹងខិតខំកាត់បន្ថយផលរំខាន និងសកម្មភាពសាងសង់នៅអគារចំណតរថយន្ត និងកាត់បន្ថយផលប៉ះពាល់ដល់បងប្អូនដែលមកកំសាន្តនៅឧទ្យាន Harvey Milk Promenade Park។

ក្រុមហ៊ុនម៉ៅការសាងសង់ សូមឲ្យបងប្អូនដែលមកលេងកំសាន្តនៅឧទ្យាន មេត្តាមើលកូនៗកុំឲ្យមកជិតតំបន់សាងសង់ និងកុំមកក្បែរកន្លែងសកម្មភាពសាងសង់។

យើងខ្ញុំសូមថ្លែងអំណរគុណបងប្អូនទុកជាមុន ចំពោះការអត់ធ្មត់ និងកិច្ចសហការក្នុងអំឡុងពេលសាងសង់នេះ។ សម្រាប់ព័ត៌មានបន្ថែម សូមបងប្អូនចូលមើល៖ longbeach.gov/cityplacemuralproject, ឬសរសេរអ៊ីម៉ែលទៅ Monica.DerGevorgian@longbeach.gov, ឬទូរស័ព្ទ (562) 570-7211។

This document is available in Spanish, Khmer and Tagalog. (email contactlbpw@longbeach.gov)
Este documento está disponible en español, tagalo y jemer. (email contactlbpw@longbeach.gov)
ឯកសារនេះអាចមានជាភាសាអេស្ប៉ាញ តាហ្គាឡុក និងខ្មែរ។ (email contactlbpw@longbeach.gov)
Ang dokumentong ito ay available sa Espanyol, Tagalog, at Khmer. (email contactlbpw@longbeach.gov